ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទទឹងថ្ងៃសម្រាប់រយៈពេល ០៣ ឆ្នាំ

(ខែ មីនា ឆ្នាំ ២០២០ ដល់ ខែមីនា ឆ្នាំ ២០២៣)

| | |
|---|---|
| សហគមន៍នេសាទ | ៖ ទទឹងថ្ងៃ |
| ភូមិ | ៖ ភូមិទទឹងថ្ងៃ |
| ឃុំ | ៖ បឹងទូក |
| ស្រុក | ៖ ទឹកឈូ |
| ខេត្ត | ៖ កំពត |

ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២០

# មាតិកា

**១.ស្ថានភាពទូទៅ** ........ ៤
**២.អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ........ ៤
ក.ប្រជាពលរដ្ឋ ........ ៤
ខ.សេដ្ឋកិច្ចសង្គម ........ ៥
**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ៥
ក.ទីតាំង ........ ៥
ខ.ដែននេសាទ ........ ៦
គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៦
ឃ. ធនធានជលផល ........ ៦
១.ប្រភេទត្រី ........ ៦
២.ប្រភេទវារីសត្វ ........ ៦
៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ........ ៧
**៤.ការធ្វើនេសាទ** ........ ៧
ក.អ្នកនេសាទ ........ ៧
ខ.ឧបករណ៍នេសាទ ........ ៧
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៩
**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៩
ក.ទស្សនៈវិស័យ ........ ៩
ខ.គោលបំណង ........ ៩
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៩
គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៩
គ.២.ផែនការចុះល្បាត ........ ១០
គ.៣.ផែនការកែលំអរដែននេសាទ ........ ១១
គ.៤.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ១១
គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង ........ ១២
គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១៣
គ.៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១៣

គ.៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ..........................១៤
គ.៩.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ..........................១៥
គ.១០. ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..........................១៥
**ឃ.យុទ្ធសាស្ត្រ**..........................១៦

**៦.ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធសង្ខេប: ១.តារាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ ២០២០-២០២៣

២.តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទទទឹងថ្ងៃក្នុងរយៈពេល ០៣ ឆ្នាំ (ខែមីនា ឆ្នាំ២០២០- ខែមីនា ឆ្នាំ ២០២៣)

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទទឹងថ្ងៃ

## ១- ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការដែលជាយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាពនិងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍និងធ្វើឱ្យធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមកភូមិទទឹងថ្ងៃ ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ ដូចនេះសហគមន៍នេសាទទទឹងថ្ងៃ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៧ខែឧសភាឆ្នាំ២០០៥ ព្រមទាំងត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ដែលទើបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី១ ដែលនឹងអនុវត្តចាប់ពីខែមីនាឆ្នាំ២០២០ ដល់២០២៣។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោត រហូតមកដល់ពេលបច្ចុប្បន្ន មានសមាជិកសរុបចំនួន១២០គ្រួសារ ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួន ដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះ សមាជិកគណៈកម្មការសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារ ទស្សនៈកិច្ចសិក្សានិងរៀនសូត្រតាមឯកសារផ្សេងៗ។

ដូច្នេះផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទទឹងថ្ងៃបានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ ពីធនធានជលផលប្រកបដោយនិរន្តរភាពនិងសមធម៌។

## ២- អំពីប្រជាសាស្រ្តនិងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំបឹងទូកមានចំនួន០២ភូមិគឺ ភូមិកែបថ្មី និងភូមិទទឹងថ្ងៃ ដោយឡែកសហគមន៍នេសាទទទឹងថ្ងៃគ្របដណ្តប់តែមួយភូមិ គឺភូមិទទឹងថ្ងៃដែលមានប្រជាពលរដ្ឋសរុបចំនួន៤៧៣គ្រួសារ ហើយគ្រួសារដែលមានស្រ្តីជាមេគ្រួសារមានចំនួន៩៦គ្រួសារ និងមនុស្សសរុបចំនួន១៤៨០នាក់ ក្នុងស្រ្តីមានចំនួន៦៨៨នាក់។

សហគមន៍នេសាទទទឹងថ្ងៃស្ថានភាពដូចជា៖

- កតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅភូមិទទឹងថ្ងៃបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ១ មានចំនួន១៩គ្រួសារ ក្នុងនោះស្រ្តីចំនួន១៨គ្រួសារ និងស្ថានភាពក្រីក្រ២ មានចំនួន៤០គ្រួសារ ក្នុងនោះស្រ្តីចំនួន២៣គ្រួសារ ដែលសរុបចំនួន៥៩គ្រួសារ
- ចំនួនស្រ្តីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន២២នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន៥នាក់

- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន៥នាក់ ក្នុងនោះស្ត្រីចំនួន២នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន១៥នាក់ក្នុងនោះស្ត្រីមានចំនួន១៣នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០៩នាក់ ក្នុងនោះស្ត្រីមានចំនួន៦នាក់
- សាលារៀនបឋមសិក្សាសរុប១មានចំនួន១ខ្នង ដែលមាន៥បន្ទប់ហើយមានសិស្សសរុបចំនួន ១៤៧នាក់ ក្នុងនោះកុមារីមានចំនួន៦៤នាក់ ។
- ចំនួនគ្រួសារដែលកើតមេរោគអេដ៍មានចំនួន៣នាក់ ក្នុងនោះស្ត្រីមានចំនួន៣នាក់។
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបឹងទូក នៅក្នុងសហគមន៍នេសាទនេះបានបង្ហាញថា១៥នាក់ ដែលមិនចេះអក្សរ ក្នុងនោះស្ត្រីចំនួន១៣នាក់។

**ខ.សេដ្ឋកិច្ចសង្គម**

តាមរបាយការណ៍និងឯកសារព័ត៌មានឃុំឆ្នាំ២០២០បានបញ្ជាក់ថា នៅក្នុងសហគមន៍នេសាទទទឹងថ្ងៃ មានប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកលើការធ្វើនេសាទ ចិញ្ចឹមសត្វ ធ្វើស្រែ កម្មករនិងលក់ដូរ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបង ដែលជួយពង្រឹកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្ម លើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វនិងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀត ដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទទទឹងថ្ងៃ ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិតនិងមុខរបរសំខាន់ៗរួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | កំណត់ចំណាំ |
|---|---|---|---|
| ១ | អ្នកដែលមានមុខរបរពឹងផ្អែកលើការនេសាទប្រហែល | ១៣១ | |
| ២ | អ្នកដែលធ្វើនេសាទ ធ្វើស្រែនិង អ្នកចិញ្ចឹមសត្វប្រហែល | ២២៥ | |
| ៣ | អ្នកកែច្នៃបង្គាក្រៀម | ១ | |
| ៤ | កម្មករ | ១៦៥ | |
| ៥ | អ្នកលក់ដូរ | ៨ | |

**៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក.ទីតាំង**

សហគមន៍នេសាទទទឹងថ្ងៃ មានទីតាំងស្ថិតក្នុងភូមិទទឹងថ្ងៃដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ហើយដែននេសាទនៅជាប់សមុទ្រដែលស្ថិតក្នុងឃុំបឹងទូក ស្រុកទឹកឈូក ខេត្តកំពត។ សហគមន៍នេសាទទទឹងថ្ងៃត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។

ដូចនេះ សហគមន៍នេសាទទទឹងថ្ងៃមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងជាប់នឹងភូមិតាងឹប
- ខាងត្បូងជាប់នឹងឆ្នេរសមុទ្រ
- ខាងកើតជាប់នឹងព្រៃកត្រើយកោះ
- ខាងលិចជាប់នឹងសហគមន៍នេសាទកែបថ្មី។

**ខ.ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទទទឹងថ្ងៃ មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទទំហំ៧៧៦ហិកតា ហើយមានដែននេសាទតំបន់ឆ្នេរនិងព្រៃកដូចជា៖

| ល.រ | ឈ្មោះព្រៃក | ទំហំ | ការនេសាទ |
|---|---|---|---|
| ១ | ព្រៃកតាងឹម | ២០០០ម x ២០ម | ពេញមួយឆ្នាំ |

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទទទឹងថ្ងៃ បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សព្រៃកោងកាងមួយកន្លែងដែលមានទំហំប្រហែល១៥ហិកតា។ ដូចនេះផងដែរ កន្លែងអភិរក្សនេះត្រូវបានធ្វើការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទមានដូចខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហត | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្សព្រៃកោងកាង | ១៥ | ការអភិរក្សធនធានជលផល |
| ២ | អាវតាប៊ូ | ៥ | អភិរក្សស្មៅ ផ្កាថ្ម និងត្រីគ្រប់ប្រភេទ |

**ឃ.ធនធានជលផល**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្ដល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីគណៈកម្មការនិងសមាជិកសហគមន៍នេសាទទទឹងថ្ងៃបានឱ្យដឹងថាពេលបច្ចុប្បន្ននេះ ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុជា ពិសេស ការចាក់ដីលុបលើកន្លែងអភិរក្សរបស់សហគមន៍នេសាទទទឹងថ្ងៃ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារនិងសមាជិកសហគមន៍លើធនធានជលផលក្នុងសហគមន៍នេសាទទទឹងថ្ងៃមានដូចជា៖

**ឃ.១.ប្រភេទត្រីសមុទ្រ:**

ក្នុងសហគមន៍នេសាទទទឹងថ្ងៃមានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកឺយ ត្រីចង្កោមបី ត្រីជំឡូង ត្រីប្លាធូ ត្រីក្តចិន ត្រីស្តុងក្រហម ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីគិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្លាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូន ត្រីសេក ត្រីតក់កែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

**ឃ.២.ប្រភេទវារីសត្វសមុទ្រ:**

ក្នុងសហគមន៍នេសាទទទឹងថ្ងៃនេះ មានប្រភេទវារីសត្វដូចជា៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹកគ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ទាយ បាលង្ក័កាស កញ្ជ អន្ទង់ ខ្ចឹង។ល។

### ឃ.៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ:

ក្នុងសហគមន៍នេសាទទទឹងថ្ងៃ មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ផ្កាថ្ម ស្មៅសមុទ្រ និង តំបន់ព្រៃកោកាងមានដូចជា៖ ព្រៃកោងកាង ក្រញឹម អម្ល អម្ពា ក្របាញ់ញី ក្របាញ់ឈ្មោល បឹង ប្រសាក ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ក្រវាញ ទំពារ។ល។

## ៤-ការធ្វើនេសាទ

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងគណៈកម្មការនិងសមាជិកសហគមន៍នេសាទទទឹងថ្ងៃ បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍ទទឹងថ្ងៃមានដូចខាងក្រោម៖

### ៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៣១នាក់ ក្នុងនោះស្ត្រីមានចំនួន៥៧នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៦៥នាក់ ក្នុងនោះស្ត្រីមានចំនួន៣៣នាក់ ។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកសហគមន៍មានប្រហែល ៧៦នាក់ ក្នុងនោះស្ត្រីប្រហែលចំនួន៣២នាក់ ក្នុង១ឆ្នាំ។

### ៤.ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | មងត្រីថ្ពោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៦ | សន្ទូចត្រីអន្លែងប៉ុយ | ផ្លែ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ៧ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៨ | មងត្រីកន្ទាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ៩ | រនងខ្សងដាក់មឹក | ខ្សង | | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៣៥ | ៧០០-១០០០ | ២៤ ដល់ ៦០ |
| ទូកចែវ | ០៥ | ៧០-១០០ | |

## ឧបករណ៍នេសាទនិងទូក កាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៦ | សន្ទូចត្រីអន្លែងប៉ុយ | ផ្លែ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ៧ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៨ | មងត្រីកន្លាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ៩ | រនងខ្យងដាក់មឹក | ខ្សែ | | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ២០ | ៧០០-១០០០ | ២៤ ដល់ ៦០ |
| ទូកចែវ | ២៥ | ១០០ | |

## ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៦ | មងត្រីកន្លាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីនលើ | ៦៥ | ៧០០-១០០០ | ២៤ ដល់ ៦០ |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ១១៣ | ៩៨ | ២១១ |
| បង្គា | ៦៧ | ៩៩ | ១៦៦ |
| ក្តាម | ៧៦ | ៨៥ | ១៦១ |
| មឹក ខ្យង និងក្រែងឈាម | ៦៥ | ៧៣ | ១៣៨ |
| **សរុប** | **៣២១** | **៣៥៥** | **៦៧៦** |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**ក.ទស្សនៈវិស័យ**

សហគមន៍នេសាទទទឹងថ្ងៃ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ.គោលបំណង**

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ក្នុងរដូវទឹកជោរនិងព្រៃកោងកាងនិងការគ្រប់គ្រងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

**គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ**

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ទទឹងថ្ងៃគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទនិងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

**ទីតាំង ឬកន្លែងនេសាទ**

| ល.រ | ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | ដែននេសាទផ្សេងៗក្រៅពីតំបន់អភិរក្សរបស់សហគមន៍នេសាទទទឹងថ្ងៃ | ពេញមួយឆ្នាំ | មងបង្គា មងត្រី លបក្តាម ឈិបរុញ សន្ទូចមឹក រនងខ្សង ។ល។ | អនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ២០១៥ |

**គ.២. ផែនការចុះល្បាត**

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការនិងសមាជិកសហគមន៍ ប៉ុន្តែការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមកការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួចពីព្រោះថា ខ្វះមធ្យោបាយល្បាត។ ដូចនេះ គណៈកម្មការនិងសមាជិកសហគមន៍នេសាទទទឹងថ្ងៃបានគ្រោងរៀបចំផែនការល្បាតក្នុងគោលបំណង៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួយបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| លរ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ២០០.០០០ (២ដង/ឆ្នាំ) | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២០ | ២០២០ |
| ២ | រៀបចំមធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឺត | ២.០០០.០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធអង្គការដៃគូ | ២០២០ | ២០២០ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ១០០.០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័ | ២០២០ | ២០២៣ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផលនិងជំនាញពាក់ព័ន្ធ | ៥.០០០.០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២០ | ២០២៣ |

### គ.៣.ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារឱ្យមានការគាំទ្របច្ចេកទេសនិងថវិកា ប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះ វាពាក់ព័ន្ធជាមួយត្រីមេពូជនិងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការនិងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាននិងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទទទឹងថ្ងៃមានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកត្តាមនុស្សនិងធម្មជាតិ។

ផែនការកែលំអដែននេសាទក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ធ្វើឱ្យសំបូរព្រៃកោងកាងឱ្យនៅក្នុងដែននេសាទសហគមន៍ និង
- ទាក់ទាញភ្ញៀវទេសចរណ៍។

ផែនការកែលំអដែននេសាទនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះ ដែននេសាទ | ទំហំ(ហត) | ទំហំដែលត្រូវកែលំអរ(ហត) | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១ | កន្លែងភក់ | ០៧ | ៥០០មx២០ម | ស្តារកន្លែងភក់ | ២០២០ | ២០២៣ |

### គ.៤.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទទទឹងថ្ងៃ បានសម្រេចបង្កើតកន្លែងអភិរក្សមួយកន្លែង ដែលមានទំហំប្រហែល៧ ហិកតា ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទទទឹងថ្ងៃ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយវាបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃកោងកាង ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាននិងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការនិងសមាជិកសហគមន៍នសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទទទឹងថ្ងៃបានសម្រេចបង្កើតកន្លែងអភិរក្សដែលពុំអនុញ្ញាតិទូកនេសាទ ឬកាណូតធ្វើការឆ្លងកាត់ក្នុងកន្លែងអភិរក្សនេះដែលជាកន្លែងសំខាន់បំផុត សម្រាប់ធ្វើការអភិរក្សធនធានជលផលដែលសមាជិសហគមន៍នេសាទ មានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះ សហគមន៍នេសាទទទឹងថ្ងៃបានសម្រេចបង្កើតកន្លែងអភិរក្សដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហត | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្ស | ០៧ | ការអភិរក្សស្មៅ ផ្កាថ្ម និងត្រីគ្រប់ប្រភេទ |
| **សរុបទំហំគិតជាហិកតា** | | **០៧** | |

កន្លែងអភិរក្ស ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ង់ព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្ដាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយនិងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| កន្លែងអភិរក្ស | ០៧ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មួន | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលស៊ីម៉ង់ ៦ ដើម<br>• ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០២០ | ២០២៣ |

**គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង**

ផែនការគ្រប់គ្រងព្រៃកោងកាងក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

ខាងក្រោមនេះជាផែនការដាំព្រៃកោងកាងក្នុងសហគមន៍នេះមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំ ហត | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ដាំកូនព្រៃកោងកាង | ១ | ព្រៃកោងកាង | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ១៥/៩/២០ | ៣០/៥/២០ |
| | | | • រៀបចំកូនឈើ | ១២/៧/២០ | ៧/៩/២០ |
| | | | • ពិធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ | ១០/១០/២០ | ១៣/១០/២០ |
| | | | • ថែរក្សា និងការពារ | ១៣/១០២០ | ៣០/៥/២២ |
| ថែរក្សា និការពារព្រៃកោងកាង | ១០ | | • ផ្សព្វផ្សាយផែនការ គ្រប់គ្រងព្រៃលិចទឹក<br>• ដាក់ស្លាកសញ្ញាការពារ<br>• ត្រួតពិនិត្យ និងការពារ | ១២/២០ | ៣១/០៣/២៣ |

## គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ៣២៥ប្រក កសកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្ពោរដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ កន្លងមកសមាជិកសហគមន៍នេសាទទទឹងថ្ងៃពុំអនុវត្តការចិញ្ចឹមត្រីសមុទ្រនិងទឹកសាបឡើយ។ ដូចនេះ ដើម្បីឆ្លើយតបនឹងត្រូវការសមាជិកសហគមន៍នេសាទទទឹងថ្ងៃមានផែនការអភិវឌ្ឍន៍វារីវប្បកម្មចិញ្ចឹមក្តាមសេះ និងគ្រែងឈាមក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការនិងសមាជិកសហគមន៍នេសាទបានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទ | បរិមាណ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូផល |
| ចិញ្ចឹមក្តាមសេះដែលបច្ចេកទេសជាលក្ខណៈជាក្រុម | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបែចិញ្ចឹម<br>• ផ្តល់មេក្តាមពង<br>• តាមដានត្រួតពិនិត្យ | ១ បែ = ៥ម x ៣ម x ២,៥ម<br>**សរុប ៥បែ** | មេក្តាមពង | ៣៥០ ក្បាល/បែ | ៧/២០ | ៣/២៣ |
| ចិញ្ចឹមគ្រែងឈាមតាមបច្ចេកទេសជាលក្ខណៈសហគមន៍ | សមាជិកសហគមន៍ | ១ហិកតា | កូនគ្រែងឈាម | ១០០ គក | ៧/២០ | ៣/២៣ |

## គ.៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាពនិងចំណេះដឹងដូចជា ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍នេសាទ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការ ដោយបានប្រើនិតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហ

គមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវនិងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ គឺថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ
- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍និងអ្នកពាក់ព័ន្ធ។

ឆ្លើយតបទៅនឹងការពង្រឹងសមត្ថភាព គណៈកម្មការនិងសមាជិកសហគមន៍នេសាទ បានរៀបចំផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទដូចខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០២០ | ២០២០ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០២១ | ២០២១ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២១ | ២០២១ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២២ | ២០២២ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២៣ | ២០២៣ |

### គ.៨. ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍នេសាទទទឹងថ្ងៃកំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃកោងកាងនិងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត គណៈកម្មការនិងសមាជិកសហគមន៍នេសាទបានរៀបចំផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០២០-២០២៣ | | | តម្លៃប៉ាន់ស្មាន (គិតជារៀល) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល | ៤ | ៤ | ៤ | ២.០០០.០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ ក្រុមប្រឹក្សាសង្កាត់ |
| ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | ស.ន | ៤ | ៤ | ៤ | ៧៥០.០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ សង្កាត់ |

## គ.៩.ផែនការបង្កើតស្នាក់ការនិងបណ្ណាល័យសហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទទទឹងថ្ងៃពុំទាន់មានស្នាក់ការនៅឡើយ ហើយគណៈកម្មការមានការលំបាកក្នុងពេលបំពេញការងារក៏ដូចជា ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ស្នាក់ការនិងបណ្ណាល័យ គួរត្រូវបានបង្កើតឡើងនិងបំពាក់សម្ភារៈមួយចំនួនដូចជា តុ កៅអីនិងទូឯកសារ។ គម្រោងស្នាក់ការនិងបណ្ណាល័យមានដូចខាងក្រោម៖

| សកម្មភាព | ទីតាំងគម្រោង | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|
| គម្រោងស្នាក់ការ | ស.ន | ៦/២០ | ៣/២៣ | ១៥.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| គម្រោងបណ្ណាល័យ | ស.ន | ១/២១ | ៣/២៣ | ៧.៨០០.០០០ | |
| សរុប | | | | ២២.៨០០.០០ | |

## គ.១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

ដោយឡែក គណៈកម្មការសហគមន៍នេសាទទទឹងថ្ងៃ ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាសង្កាត់និងការធ្វើទស្សនៈ កិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

ដូចនេះ ផែនការស្វែងរកថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេះមានក្នុងតារាងខាងក្រោម៖

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|
| ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ផ្សព្វផ្សាយនិងបណ្ណភាគទាន | ខែ៣/២០ | ខែ៣/២៣ | ១.២០៧.០០០ |
| ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណភាគទាន | ខែ៣/២០ | ខែ៣/២៣ | ៣.១៦០.០០០ |
| សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុគរបរ<br>• ជាថវិកាផ្ទាល់ | ខែ៣/២០ | ខែ៣/២៣ | ២.៣៥០.០០០ |
| ក្រុមប្រឹក្សាសង្កាត់ | ការពារធនធាធម្មជាតិ | ខែ៣/២០ | ខែ៣/២៣ | ៧៥០.០០០ |

**ឃ.យុទ្ធសាស្ត្រ**

នៅក្នុងសហគមន៍នេសាទទទឹងថ្ងៃ ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- គណៈកម្មការត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួមនិងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគោការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទឹងថ្ងៃរយៈពេល ០៣ ឆ្នាំ (ខែមីនា ឆ្នាំ២០២០- ខែមីនា ឆ្នាំ ២០២៣)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ច |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | •កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>•កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>•សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | ១.៥០០.០០០ | | ២០២០ | ២០២៣ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/២ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១.៥០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធនឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ | | | | |
| ១.៣.ត្រួតពិនិត្យនិងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើលនិងរាយការណ៍ | | | | |
| **២.ផែនការចុះល្បាត** | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួយបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | ៧,៣០០,០០០ | | | |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់និងរៀបចំសម្រាប់អនុវត្ត | ២០០.០០០ | | | |
| ២.២.រៀបចំមធ្យោបាយនិងសម្ភារៈ | មធ្យោបាយនិងសម្ភារៈបានគ្រោងនិងរៀបចំ | ២.០០០.០០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ១០០.០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ៥.០០០.០០០ | | | |
| **៣.ផែនការកែលំអដែននេសាទ** | •បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទនិងព្រៃកោងកាង<br>•ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>•មានភ្ញៀវទេសចរណ៍និងផ្តល់ការងារដល់សហគមន៍<br>•សហគមន៍មានដើមទុនសម្រាប់ខ្លួនឯង | ៩.០០០.០០០ | | | |
| ៣.១.ផែនការស្តារកន្លែងដែលរាក់ ៥០០មX២០ម | •ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>•ធ្វើការសិក្សាលើទំហំដែលត្រូវស្តារនិង | ៩.០០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| **៤.ផែនការរៀបចំកន្លែងអភិរក្ស** | •ប្រភេទត្រីមេពូជនិងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ | ៩.២៨០.០០០ | | | |

| | | | | | |
|---|---|---|---|---|---|
| | •ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | | | | |
| ៤.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្ស ៧ហិកតា | ចំនួន១២បង្គោលនឹងបានបោះនៅកន្លែងអភិរក្ស ដោយមានផែនទីសំគាល់កន្លែងអភិរក្ស | ៥.០០០.០០០ | | ២០២០ | ២០២៣ |
| ៤.២.ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ២០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៤.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០១ស្លាកផ្ទាំងប៉ាណូនឹងបោះសម្រាប់ផ្សព្វផ្សាយ | ១.២០០.០០០ | | | |
| ៤.៤ សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មX៥ម | ១.៨០០.០០០ | | | |
| ៤.៥ ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនឹងថយចុះតាមរយៈការចុះល្បាត | ១.០៨០.០០០ | | | |
| **៥.ផែនការគ្រប់គ្រងព្រៃកោងកាងទំហំ១០ហិកតា** | •សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃកោងកាង<br>•ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | **៣.០០០.០០០** | | | |
| ៥.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយាជន៍ព្រៃកោងកាង | ២០០.០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ៥.២.ថែរក្សា និងការពារព្រៃកោងកាង | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់និងដាក់ស្លាកសញ្ញាការពារ | ៨០០.០០០ | | | |
| ៥.៣.ផែនការដាំកូនព្រៃកោងកាងទំហំផ្ទៃដី១ហិកតា | រៀបចំថ្នាលកូនឈើ ពីធីដាំកូនឈើនិងដាក់ស្លាកសញ្ញាការពារ ថែរក្សា ការពារ | ១.០០០.០០០ | | | |
| ៥.៤.ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បផ្លាញ់ព្រៃកោងកាងនឹងត្រូវបានទប់ស្កាត់ | ១.០០០.០០០ | | | |
| **៦.ការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត | | | | |
| **៦.១.ការចិញ្ចឹមក្ដាមសេះ តាមបច្ចេកទេសជាលក្ខណៈជាក្រុម** | | **៤.០០០.០០០** | | | |
| ៦.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២៥គ្រួសារត្រូវបានជ្រើសរើស | ៣.០០០.០០០ | ដៃគូអភិវឌ្ឍន៍ សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៦.១.២.បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹម | ចំនួន២៥គ្រួសារ នឹងត្រូវបានបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមត្រឹមត្រូវ | | | | |
| ៦.១.៣.ធ្វើបែចិញ្ចឹម | ចំនួន៥បែ ដែលក្នុង១បែមានទំហំ៥មX៣មX២,៥ម ត្រូវបានសាងសង់ | | | | |
| ៦.១.៤.ការដាក់មេក្ដាមពង | មេក្ដាមពងនឹងត្រូវបានផ្ដល់៥ក្រុម | | | | |
| ៦.១.៥.ត្រួតពិនិត្យតាមដាន | ក្រុមចិញ្ចឹមក្ដាមនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.២.ចិញ្ចឹមត្រីគក់កែតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន៦គ្រួសារ** | | | | | |
| **៦.២ ចិញ្ចឹមគ្រែងឈាមតាមបច្ចេកទេសជាលក្ខណៈសហគមន៍** | | | | | |
| ៦.២.១.ផ្សព្វាយដល់សមាជិកសហគមន៍ | សមាជិកសហគមន៍ស្ម័គ្រចិត្តត្រូវបានជ្រើសរើស | ១.០០០.០០០ | | | |
| ៦.២.២.បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមគ្រែឈាម | សមាជិកសហគមន៍នឹងត្រូវបានបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹម | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.៣ រៀបចំកន្លែងចិញ្ចឹមគ្រែឈាម | កន្លែងចិញ្ចឹមគ្រែឈាមមានទំហំ ១ ហិកតា ត្រូវបានរៀបចំ | | | | |
| ៦.២.៤.ការដាក់កូនគ្រែឈាម | ចំនួនកូនគ្រែឈាម ១០០ គក នឹងត្រូវបានដាក់ក្នុងកន្លែងចិញ្ចឹម | | | | |
| ៦.២.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ធ្វើការត្រួតពិនិត្យការចិញ្ចឹមគ្រែឈាម | | | | |
| **៧.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | •គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>•យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់និង<br>•បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១.៣០០.០០០** | | | |
| ៧.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២០ | ២០២០ |
| ៧.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកានឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | | ២០២១ | ២០២១ |
| ៧.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២២ | ២០២២ |
| ៧.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០២២ | ២០២២ |
| ៧.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២៣ | ២០២៣ |
| **៨.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ និងកសាងសមត្ថភាពគណៈកម្មការ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **២.៧៥០.០០០** | | | |
| ៨.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹងផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋាន | ២.០០០.០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២០ | ២០២៣ |
| ៨.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈនិងបបញ្ជាផ្ទៃក្នុង | ៧៥០.០០០ | | | |
| **៩.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ** | | **២២.៨០០.០០០** | | | |
| ៩.១.បង្កើតស្នាក់ការ | ស្នាក់ការរបស់សហគមន៍នឹងត្រូវបានជួសជុល | | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២០ | ២០២៣ |
| ៩.២.បំពាក់សម្ភារៈ | សម្ភារៈកៅអីនិងទូឯកសានឹងត្រូវបានបំពាក់ | ១៥.០០០.០០០ | | | |
| ៩.៣.គម្រោងសាងសង់បណ្ណាល័យ | បណ្ណាល័យនឹងត្រូវបានសាងសង់ | ៧.៨០០.០០០ | | | |
| **១០.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ** | | **១៤.៣៣៧.៥០០** | | | |
| ១០.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១.៣៣៧.៥០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២០ | ២០២៣ |
| ១០.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | | | |
| ១០.៣.អំណោយពីសប្បុរសជននិងអង្គការដៃគូ | សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | ៤.០០០.០០០ | | | |
| ១០.៤.ក្រុមប្រឹក្សាសង្កាត់ | មូលនិធិរបស់សង្កាត់-ឃុំ | ៧៥០.០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទទឹកប្រៃក្នុងរយៈពេល ០៣ ឆ្នាំ (ខែមីនា ឆ្នាំ២០២០- ខែមីនា ឆ្នាំ ២០២៣)

| សកម្មភាព | ២០២០ | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | | ២០២៣ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | |
| | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 |
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការកែលំអរដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ការពង្រឹងសមត្ថភាពគណៈកម្មការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ផែនការបង្កើតស្នាក់ការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |



សូមគោរពជូន
លោកមេឃុំបឹងទូក
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃសុក្រ ០៦ កើត ខែមាឃ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
កំពត ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២០
**ប្រធានគណៈកម្មការសហគមន៍នេសាទធនធានបឹងទូក**

ការ៉ុន - ទូច

លេខ: ០៥៧ /២០
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផល
ក្បាលរមាស
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃសុក្រ ០៦ កើត ខែមាឃ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២០
**ជ.មេឃុំ**
**មេឃុំ**

ប៉ែន ធន្លា

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ ខែមាឃ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
ថ្ងៃទី.........ខែ............ឆ្នាំ២០២០
**នាយសង្កាត់រដ្ឋបាលជលផលក្បាលរមាស**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ ១៣ កើត ខែមាឃ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០
**នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត**

អុន - ឆៃ

លេខ: ១១៧
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ សុក្រ ៣ រោច ខែ ផល្គុន ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
កំពត ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០
**នាយខណ្ឌរដ្ឋបាលជលផលកំពត**

ស សុរិន

លេខ ២៤៥ /២០ កស.កព
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ ពុធ ៣ រោច ខែ ចេត្រ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
កំពត ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០២០
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត**

ចាន់ រិទ្ធិ

លេខ........................
បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំកុរឯកស័ក,ព ស ២៥៦៣
រាជធានីភ្នំពេញ .ថ្ងៃទី...............ខែ.........................ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន